ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០០១ ដនស/សរជ

# សារាចរណែនាំ

## អនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
## ( ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ )

អនុលោមតាមអនុក្រឹត្យលេខ ៤៦អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ :

ដំណាក់កាលទី១ : អំពីការរៀបចំ

១.- បន្ទាប់ពីបានពិភាក្សាឯកភាព ជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្ត ក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

២.- នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ឱ្យទៅបំពេញភារកិច្ចនៅក្នុងតំបន់វិនិច្ឆ័យនោះ ។ ទន្ទឹមនឹងនេះ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុងពាក់ព័ន្ធនឹងតំបន់វិនិច្ឆ័យ ក៏ត្រូវចាត់តាំងមន្ត្រីម្នាក់ឱ្យទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីជូនអភិបាលខេត្ត ក្រុង ដើម្បីបញ្ចូលជាសមាជិកនៃគណៈកម្មការរដ្ឋបាលផងដែរ ។

៣.- យោងតាមចំណាត់តាំងខាងលើ អភិបាលខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការរដ្ឋបាលសំរាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ ទៅតាមសមាសភាពដែលបានកំណត់ក្នុងអនុក្រឹត្យ។ /